# អភិក្រមខាងអភិបាលកិច្ចសម្រាប់សហគមន៍ជីកយករ៉ែមាសជាលក្ខណៈសិប្បកម្ម

## *ទ្រទ្រង់ការចិញ្ចឹមជីវិត និងពង្រឹងឱកាសខាងសង្គមនៅបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក*

**Samuel Spiegel**

*សកលវិទ្យាល័យ ខេមប្រ៊ីច*

samspiegel@gmail.com

*សន្និសីទអន្តរជាតិស្តីពីអាជីវកម្មរ៉ែ “ឱកាសសម្រាប់កម្ពុជា” - ភ្នំពេញ ថ្ងៃទី **26-27** ខែ ឧសភា ឆ្នាំ **2010***





# គោលបំណងចំបងនៃបទបង្ហាញ

## របកគំហើញពីការសិក្សាមួយដែលចាត់ចែងឡើងដោយ UNDP

- *ការពិនិត្យអំពីការប្រឈមចំបងៗខាងអភិបាលកិច្ច នៅក្នុងវិស័យយករ៉ែជាលក្ខណៈសិប្បកម្ម ‑ តើ "ការប្តូរទៅអភិក្រមនៃការចិញ្ចឹមជីវិត" មានន័យបែបណា*
  - ធ្វើឱ្យអ្នកជីករ៉ែតាមបែបសិប្បកម្មដែលជាកម្មករនៅក្នុង"វិស័យមិនផ្លូវការ"បានចូលរួម ជាងចាត់ទុកថា "ល្មើសច្បាប់"
  - ការធ្វើអត្តសញ្ញាណកង្វល់/អាទិភាពចំបងៗ ដែលលើកឡើងដោយកម្មករអណ្តូងរ៉ែក្រីក្រ
  - លើកកំពស់សមធម៌ខាងសង្គម និងបរិស្ថាន នៅក្នុងតំបន់ជីកយករ៉ែជាលក្ខណៈសិប្បកម្ម
- *បង្ហាញពីមេរៀនជាក់លាក់ពីកម្មវិធីជំនួយអភិវឌ្ឍន៍នានា*
  - កំណែទម្រង់គោលនយោបាយថ្មីៗនេះនៅតំណ្ឌូនេស៊ី ‑ (a) ដើម្បីធ្វើឱ្យ"ការជីករ៉ែដោយប្រជាជន" (ការជីកយករ៉ែទ្រង់ទ្រាយតូច) ក្លាយជាស្របច្បាប់ និង (b) ដាក់បញ្ញត្តិលើការគ្រប់គ្រងបរិស្ថាន
  - បទពិសោធន៍ថ្មីៗនេះស្តីពីបញ្ហាគោលនយោបាយ និងបច្ចេកវិទ្យា នៅក្នុងប្រទេសឡាវ
- *លើកស្នើយុទ្ធសាស្ត្រនានាសម្រាប់ការកសាងសមត្ថភាព ការបណ្តុះបណ្តាល និងកិច្ចសហការនៅក្នុងសហគមន៍អ្នកយករ៉ែមាស*

# ធ្វើឱ្យក្រុមអ្នករករ៉ែខ្នាតតូចនាំឯកក្រុមជីករ៉ែជាលក្ខណៈសិប្បកម្ម និងទ្រង់ទ្រាយតូច បានចូលរួម

- ប្រជាជន 80-100 លាននាក់ជុំវិញពិភពលោក ពឹងផ្អែកលើសកម្មភាពនេះនៅទូទាំងពិភពលោក
- ក្រុមអ្នកជីកយករ៉ែ នៅបណ្តាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក មានលក្ខណៈចម្រុះ - ស្ត្រី បុរស កុមារ ដែលធ្វើការនៅលើដី (កាត់យកផ្កាថ្ម) ក្នុងព្រៃ ក្នុងទន្លេ (លាងរ៉ែមាស)
- ធ្វើការនៅក្នុងអង្គការចាត់តាំង ក្រុម សមាគម បុគ្គលនានា គ្រួសារ
- នៅក្នុងប្រទេសខ្លះ ការជីកយករ៉ែជាទ្រង់ទ្រាយតូច ត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ - នៅលើឯកសារ (តាមទ្រឹស្តី មានអាជ្ញាប័ណ្ណសម្រាប់ប្រជាពលរដ្ឋមានដើមកំណើតក្នុងស្រុក)។ ប៉ុន្តែ សូម្បីតែមានចែងក្នុងច្បាប់ហើយក៏ដោយ ជាញឹកញាប់ សកម្មភាពទាំងនេះត្រូវបានចាត់ទុកថា "មិនស្របច្បាប់")



*ការលាងរ៉ែមាសនៅប្រទេសឡាវ*

# ឧទាហរណ៍ខ្លះៗអំពីប្រការនានាដែលចែងនៅក្នុងគោលនយោបាយ

| ប្រទេស | អាជ្ញាប័ណ្ណ/លិខិតអនុញ្ញាត | ទំហំ | រយៈពេល | បេក្ខភាពសមស្រប |
|---|---|---|---|---|
| ឡាវ | អាជ្ញាប័ណ្ណកម្រិតសិប្បកម្ម | នឹងមានបញ្ជាក់ | 1 ឆ្នាំ/នឹងមានបញ្ជាក់ | ជនជាតិឡាវ |
| | អាជ្ញាប័ណ្ណ SSM | 6 គ.ម$^2$ | 5 ឆ្នាំ | គ្មានការកំហិត |
| ឥណ្ឌូនេស៊ី | អាជ្ញាប័ណ្ណសម្រាប់ការជីកយករ៉ែដោយប្រជាជន | 1 ហិកតា សម្រាប់បុគ្គល ។ ដល់ 25 ហិកតា សម្រាប់សហគមន៍ | 5 ឆ្នាំ | ជនជាតិឥណ្ឌូនេស៊ីដែលរស់នៅក្នុងមូលដ្ឋាននោះ |
| ប៉ាពួញូហ្គីនេ | អាជ្ញាប័ណ្ណមិនផ្លូវការ | ក្នុងចំណែកដីរបស់ខ្លួន | | ម្ចាស់ដីជាជនជាតិប៉ាពួញូហ្គីនេ |
| | អាជ្ញាប័ណ្ណសម្រាប់វាលល្បាប់ | 5 ហិកតា | 5 ឆ្នាំ | ម្ចាស់ដីជាជនជាតិប៉ាពួញូហ្គីនេ |
| | ការជួលដីយករ៉ែ | 50 ហិកតា | 20 ឆ្នាំ | គ្មានការកំហិត |
| ហ្វីលីពីន | លិខិតអនុញ្ញាតត្បូងថ្មមានតម្លៃ | នឹងមានបញ្ជាក់ | 1 ឆ្នាំ | ជនជាតិហ្វីលីពីន |
| | លិខិតអនុញ្ញាតការប្រមូលយកលាមកសត្វតាមបែបពាណិជ្ជកម្ម | 5 ហិកតា | 1 ឆ្នាំ | ជនជាតិហ្វីលីពីនដែលរស់នៅក្នុងមូលដ្ឋាននោះ |
| | លិខិតអនុញ្ញាតឱ្យប្រមូលលាមកសត្វដោយឥតគិតថ្លៃ | ត្រឹម 2 តោន | អាស្រ័យលើបរិមាណប្រមូលបាន | ជនជាតិហ្វីលីពីនដែលរស់នៅក្នុងមូលដ្ឋាននោះ |
| | លិខិតអនុញ្ញាតបូមខ្សាច់ និងគ្រួសតាមបែបពាណិជ្ជកម្ម | 5 ហិកតា | 1 ឆ្នាំ | ជនជាតិហ្វីលីពីន |
| | លិខិតអនុញ្ញាតបូមខ្សាច់ និងគ្រួសជាលក្ខណៈឧស្សាហកម្ម | 5-20 ហិកតា | 5 ឆ្នាំ | ជនជាតិហ្វីលីពីនឬក្រុមហ៊ុន ដែលមាន 60% នៃដើមទុនជារបស់ជនជាតិហ្វីលីពីន |
| | លិខិតអនុញ្ញាត SSM | នឹងមានបញ្ជាក់ | 2 ឆ្នាំ | នឹងមានបញ្ជាក់ |
| | កិច្ចសន្យា SSM | 20 ហិកតា | 2 ឆ្នាំ | ជនជាតិហ្វីលីពីនឬសហគមន៍ជាតិហ្វីលីពីន |

# កង្វល់ចំបងៗ ដែលសហគមន៍អ្នកកាប់ឈើបានលើកឡើង ៖

## គម្លាតរវាង "គោលនយោបាយនៅក្នុងឯកសារ" និង ភាពជាក់ស្តែងនៅមូលដ្ឋាន

- បើទោះជាមានច្បាប់/គោលនយោបាយ សម្រាប់ការជីកយករ៉ែខ្នាតតូចក៏ដោយ គេនៅតែអាចទាញយកផលបានត្រឹមតិចតួចប៉ុណ្ណោះ ពីគោលនយោបាយទាំងនោះ
- នៅក្នុងតំបន់ភាគច្រើន គេពុំមានកម្មវិធីជំនួយណាមួយនៅឡើយទេ។ ទំនាក់ទំនងជាមួយអាជ្ញាធរ កើតមានតែនៅពេលណាមានបញ្ហាតែប៉ុណ្ណោះ (វិធានការអភិបាលកិច្ចដែលជាប្រតិកម្មតប)។ លើសពីនេះ ការសិក្សានានាបង្ហាញថា ការប្រើប្រាស់កម្លាំងនគរបាល និងយោធា ដើម្បីបង្ក្រាបសកម្មភាពទាំងនេះ អាចនាំមកនូវបញ្ហាថ្មីៗ
- អ្នកជីកយករ៉ែជាច្រើន មិនបានដឹងអំពីរបៀបដាក់ពាក្យសុំអាជ្ញាប័ណ្ណសម្រាប់ការជីកយករ៉ែឡើយ
- ចំពោះអ្នកខ្លះ ច្បាប់បង្កឱ្យមានការិយាធិបតេយ្យខ្លាំងពេក ស្មុគស្មាញពេក (ដូចជា ប្រការចែងអំពីបរិស្ថាន) និងអាចត្រូវចំណាយច្រើនពេក ដើម្បីទទួលបានអាជ្ញាប័ណ្ណ
- ជួនកាល ច្បាប់មិនអនុញ្ញាតឱ្យប្រើ "គ្រឿងយន្តពាក់កណ្តាលស្វ័យប្រវត្តិ" (ដូចជាក្នុងប្រទេសឡាវ) ផ្ទុយទៅវិញ ជួនកាល ច្បាប់តម្រូវឱ្យមានវិធីទំនើបនៅក្នុងការជីកយករ៉ែ
- គ្មានជំនួយ ឬ សេវាបណ្តុះបណ្តាលឡើយ ។

# ឥទ្ធិពលនៃការចេញច្បាប់អាជ្ញាប័ណ្ណមកលើអ្នកយករ៉ែជាលក្ខណៈសិប្បកម្ម




តើការទទួលស្គាល់ជាផ្លូវការតាមច្បាប់ អំពីការចិញ្ចឹមជីវិតរបស់អ្នកជីកយករ៉ែ ជាលក្ខណៈសិប្បកម្ម (ក្នុងតំបន់ដែលបានកំណត់) នាំឱ្យមានសកម្មភាពដែលមានសុវត្ថិភាពជាងមុន និងបច្ចេកវិទ្យាដែលមានប្រសិទ្ធិភាពខ្ពស់ជាងដែរឬទេ?





- តើមាន "ប្រការនៅក្នុងច្បាប់" ដែលអាចផ្តល់ឱកាសសម្រាប់ធ្វើការជាមួយអ្នកជីកយករ៉ែជាលក្ខណៈសិប្បកម្មដែរឬទេ?
- តើក្រុមហ៊ុនអាចធ្វើបែបណាដើម្បីធ្វើឱ្យកម្លាំងពលកម្មដែលជាអ្នកជីករ៉ែជាលក្ខណៈសិប្បកម្ម អាចចូលរួមប្រកបដោយប្រសិទ្ធិភាព?
- តើធ្វើបែបណាទើបរដ្ឋាភិបាលអាចកំណត់តំបន់ពិសេសសម្រាប់ការយករ៉ែជាលក្ខណៈសិប្បកម្ម ឱ្យមានប្រសិទ្ធិភាពទៅបាន?
- តើអាចបង្កើតប្រព័ន្ធអាជ្ញាប័ណ្ណ និងបទប្បញ្ញត្តិបែបណា ដែលអាចសិទ្ធិអំណាចដែលមានសមធម៌នៅក្នុងអាជីវកម្មនេះ?
- តើមានជំនួយខាងមីក្រូហិរញ្ញប្បទាន និងបច្ចេកវិទ្យា សម្រាប់អ្នកយករ៉ែជាលក្ខណៈសិប្បកម្មដែរឬទេ?

# ដោះស្រាយភាពទន់ខ្សោយរបស់អ្នកនៅជនបទ  ការផ្តល់សិទ្ធិអំណាចដល់ស្ថាប័ននានានៅមូលដ្ឋាន





- បទពិសោធន៍កន្លងមករបស់អ.ស.ប (ដូចក្នុងរូបខាងលើ) បង្ហាញថា ផលចំណេញនឹងកើតឡើង នៅពេលដែលរដ្ឋាភិបាល និងទីភ្នាក់ងារដទៃទៀត បង្កើតភាពជាដៃគូជាមួយក្រុមអ្នករស់នៅមូលដ្ឋាន ដើម្បីជួយអ្នកជីករ៉ែ និងកែលម្អបច្ចេកវិទ្យា
- គោលនយោបាយងាយយល់ ផ្តល់ប្រសិទ្ធិភាពខ្ពស់ជាងគោលនយោបាយស្មុំគ្រាំ។ ត្រូវមានគោលការណ៍ណែនាំជាក់លាក់សម្រាប់ការយករ៉ែជាលក្ខណៈសិប្បកម្ម (មិនដូចទម្រង់ EIA សម្រាប់ក្រុមហ៊ុនធំៗឡើយ) - ដែលជាកង្វល់លើកឡើងដោយប្រទេសជាច្រើន
- ត្រូវការឱ្យមានគោលនយោបាយដែលផ្តល់យុត្តិធម៌ ងាយយល់បាន និងបង្កើតភាពជាដៃគូជាមួយអ្នកយករ៉ែ
- បង្កើនមូលនិធិសម្រាប់ការិយាល័យស្រុក ដើម្បីផ្តល់សេវាកម្មផ្សព្វផ្សាយ នៅក្នុងតំបន់យករ៉ែ

# ទិដ្ឋភាពពីអាកាសនៃទីតាំងយករ៉ែទ្រង់ទ្រាយតូចមួយនៅ Galangan – ភាគកណ្តាលនៃកាលីម៉ាន់តាន់ ប្រទេសឥណ្ឌូនេស៊ី






“អង្គភាពបណ្តុះបណ្តាលចល័ត” សម្រាប់សាកល្បងបច្ចេកវិទ្យានៅក្នុងតំបន់យករ៉ែនានា

# ច្បាប់ថ្មីស្តីពី "ការជីករ៉ែដោយប្រជាជន" ដែលបានអនុម័តក្នុងឆ្នាំ 2006

(ភាគកណ្តាលនៃតំបន់កាលីម៉ាន់តាន់ ប្រទេសឥណ្ឌូនេស៊ី)

*ប្រការនានាដូចខាងក្រោមនេះ មានចែងនៅក្នុងច្បាប់ :*

1. *កន្លែងដែលលិខិតអនុញ្ញាតសម្រាប់ការជីកយករ៉ែដោយប្រជាជន ត្រូវបានផ្តល់ទៅឱ្យបុគ្គលណាម្នាក់ លើផ្ទៃដីរហូតដល់៥ (ប្រាំ) ហិកតា។*
2. *សហគមន៍មួយ អាចទទួលបានលិខិតអនុញ្ញាតសម្រាប់ការយករ៉ែដោយប្រជាជន នៅលើផ្ទៃដីធំបំផុត ២៥ (ម្ភៃប្រាំ) ហិកតា*
3. *បុគ្គលម្នាក់ដែលមានលិខិតអនុញ្ញាតសម្រាប់ការយករ៉ែដោយប្រជាជន រួចទៅហើយ មិនអាចអនុញ្ញាតឱ្យមានលិខិតអនុញ្ញាតមួយផ្សេងទៀតឡើយ លើកលែងតែលិខិតអនុញ្ញាតមុននោះផុតសុពលភាព [ប្រការនេះ សព្វថ្ងៃលែងមានសុពលភាពទៀតហើយ]*
4. *តំបន់សម្រាប់ការជីករ៉ែដោយប្រជាជន ត្រូវតែស្ថិតនៅលើដី និងត្រូវស្ថិតនៅចម្ងាយយ៉ាងហោចណាស់ 200 ម៉ែត្រពីច្រាំងទន្លេ*

*(បទប្បញ្ញត្តិសម្រាប់ស្រុក កាទីហ្កាន់ លេខ ៣ ឆ្នាំ ២០០៦)*

## កង្វល់សំខាន់ៗ ដែលលើកឡើងជាការឆ្លើយតបនឹង បទប្បញ្ញត្តិថ្មី :

- គោលនយោបាយនានាអាចមិនសូវពាក់ព័ន្ធ ប្រសិនបើមិនមានការកំណត់តំបន់ពិសេស
- ត្រូវគ្រោងធនធានសម្រាប់អប់រំអ្នកជីករ៉ែ អំពីរបៀបអនុវត្តតាមបទប្បញ្ញត្តិនានា
- ការធ្វើឱ្យស្របច្បាប់ អាចបង្កើតជាមូលដ្ឋានសម្រាប់កម្មវិធីកសាងសមត្ថភាពដែលគិតគូរជាមុនអំពីកត្តាបរិស្ថាន ប៉ុន្តែការបន្សុីគ្នារវាងការជីកយករ៉ែ និងអាជ្ញាធរបរិស្ថាន មានសារៈសំខាន់ណាស់។

# គោលនយោបាយថ្មីស្តីពីការគ្រប់គ្រងបារ៉ត អនុម័ត នៅឆ្នាំ 2007

(ភាគកណ្តាលនៃតំបន់កាលីម៉ាន់តាន់)

- នាយកដ្ឋានចំនួនប្រាំរបស់រដ្ឋាភិបាល រួមជាមួយបុគ្គលិកគម្រោងរបស់ អ.ស.ប បានផ្តោតលើការតាក់តែងគោលនយោបាយថ្មីស្តីពី ការគ្រប់គ្រងបារ៉ត ទន្ទឹមនឹងធ្វើយុទ្ធនាការផ្សព្វផ្សាយ ដែលលើកកំពស់ការអប់រំអំពីសុខភាពបរិស្ថាន និងការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា
- ផ្តោតជាចំបងលើហាងលក់មាស នៅតាមទីប្រជុំជន តែមិនសូវផ្តោតលើកន្លែងយករ៉ែនៅជនបទទេ
- គោលនយោបាយឆ្នាំ 2007 បានកើតឡើង តាមរយៈការពិគ្រោះយោបល់ជាមួយម្ចាស់ហាងលក់មាស អ្នកវិភាគបរិស្ថាននៅមូលដ្ឋាន អ្នកផលិតបរិក្ខារ អ្នកជីករ៉ែ និងអ្នកដទៃទៀត។



- លទ្ធផលពីកម្មវិធីនេះនៅក្នុងហាងលក់មាស បង្ហាញថាបានជោគជ័យជាខ្លាំង (ហាងមាសច្រើនជាង 40 បានប្រើប្រាស់បំពង់ស្រូបចំហាយ)។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីនេះមិនបានទទួលជោគជ័យឡើយនៅជនបទ ដោយសារមានធនធានក្នុងកម្រិតកំណត់ ហើយរដ្ឋាភិបាល នៅតែមិនមានជំហរច្បាស់លាស់អំពីរបៀបគ្រប់គ្រងសកម្មភាពជីកយករ៉ែ។

# សេចក្តីសន្និដ្ឋាន

- ការពិនិត្យមើលបញ្ហាគោលនយោបាយលើការយករ៉ែ នៅប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ុងហ្គោលី និងប្រទេសដទៃទៀតនៅអាស៊ី បង្ហាញថា ជាទូទៅ ការជជែកសព្វថ្ងៃអំពីការយករ៉ែទ្រង់ទ្រាយធំ មានឥទ្ធិពលខ្លាំងលប់លើកង្វល់អំពីសហគមន៍ជីកយករ៉ែជាលក្ខណៈសិប្បកម្ម។ ក្រុមអ្នកជីកយករ៉ែជាលក្ខណៈសិប្បកម្ម ត្រូវតែបានចូលរួមពាក់ព័ន្ធ ហើយក៏ត្រូវតែមានការទទួលស្គាល់សិទ្ធិរបស់ពួកគេផងដែរ។
- មានការលើកស្នើថា រដ្ឋាភិបាលគួរពិនិត្យឡើងវិញនូវគោលនយោបាយ និងអភិក្រមខាងស្ថាប័ន ធានាបង្កើតឱ្យមានផលប្រយោជន៍ដែល អាចកើតចេញពីនីតិវិធីខាងផ្លូវច្បាប់ និងបង្កើតកម្មវិធីសម្រាប់ធ្វើឱ្យមានការចូលរួមរបស់កម្មករក្នុងវិស័យមិនផ្លូវការ ដោយមានការគិតគូរជាមុន អំពីអ្វីដែលអាចកើតឡើងទៅអនាគតផងដែរ
- រដ្ឋាភិបាលគួរប្រកាន់យក "អភិក្រមនៃរបរចិញ្ចឹមជីវិត" ដែលផ្តល់ជោគជ័យ។ សំណើសំខាន់ៗមួយចំនួនគឺ :
  - តាក់តែងគោលនយោបាយដើម្បីបណ្តុះបណ្តាលអ្នកជីករ៉ែ (វិធីធ្វើអាជីវកម្មរ៉ែមាស ដែលមានសុវត្ថិភាព និងមានប្រសិទ្ធិភាពជាងមុន)
  - កសាងគោលនយោបាយច្បាស់លាស់អំពីការគ្រប់គ្រងបារ៉ត (ដូចជា ហាមប្រើប្រាស់បារ៉តជាមួយ ស្យានីត — សូមអាន *គោលការណ៍ណែនាំអន្តរជាតិ ស្តីពីការគ្រប់គ្រងបារ៉ត* ដែលបានរៀបរៀងឡើងនៅពេលថ្មីៗនេះ)
  - កសាងគោលនយោបាយនានា ដើម្បីគាំទ្រដល់អង្គការនានានៅមូលដ្ឋាន និងសមាគមអ្នកយករ៉ែ
  - បង្កើតបណ្តាញទីផ្សារដែលមានសមធម៌សម្រាប់ផលិតផលរ៉ែ ។ បង្កើតសេវាកម្មមីក្រូហិរញ្ញវត្ថុ
  - បង្កើនមូលនិធិសម្រាប់សេវាកម្មខាងស្ថាប័ន (ប្រហែលអាចប្រើប្រាស់ផលចំណូលពីពន្ធលើការយករ៉ែ)
  - កំណត់ទីតាំងពិសេស សម្រាប់ការជីករ៉ែជាលក្ខណៈសិប្បកម្ម និងផ្តល់ការណែនាំផងដែរ ដល់ក្រុមហ៊ុននានា អំពីវិធីធ្វើការជាមួយក្រុមអ្នកជីករ៉ែជាលក្ខណៈសិប្បកម្ម ដោយគិតគូរជាមុនអំពីអ្វីដែលអាចកើតមានទៅអនាគត
  - បង្កើតក្រុមការងារពិសេសខាងការជីកយករ៉ែជាលក្ខណៈសិប្បកម្ម ដោយមានចក្ខុវិស័យអំពីគោលនយោបាយសម្រាប់រយៈពេលវែង
- ការផ្តល់នូវកិច្ចសហការគាំទ្រ ដល់របរចិញ្ចឹមជីវិត នៅក្នុងសហគមន៍អ្នកជីករ៉ែ អាចផ្តល់នូវផលប្រយោជន៍យ៉ាងច្រើន